គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP
IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP- PJJ - VIGILANCE
#9, St.330, Boeng Keng Kong III, Chamcar Morn, P.P Tel/Fax: (023) 218 759, Tel: 30 14 15, E-mail: chrac@forum.org.kh, chracsecretariat@yahoo.com

# សេចក្តីថ្លែងការណ៍

## ការគំរាមកំហែង និង ការរំខានសកម្មភាពដល់អ្នកការពារសិទ្ធិមនុស្ស

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធអង្គការ-សមាគមមិនមែនរដ្ឋាភិបាល ២៣ ជាសមាជិក មានការសោកស្តាយចំពោះការគំរាមកំហែង និង ការរំខានដល់សកម្មភាពលើកស្ទួយ និងការពារសិទ្ធិមនុស្ស របស់អ្នកការពារសិទ្ធិមនុស្ស ដោយក្រុមសមត្ថកិច្ចប៉ូលីសខ័ណ្ឌមានជ័យ កាលពីព្រឹកថ្ងៃទី ០១ ខែមិនា ឆ្នាំ២០១០ ដែលសកម្មភាពនេះ បានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការនៃការលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

គណៈកម្មាធិការប្រព្រឹត្តិកម្ម បានទទួលព័ត៌មានថា ប្រជាពលរដ្ឋចំនួន៣៣៥គ្រួសារ ដែលរស់នៅក្នុងភូមិប្រកា សង្កាត់ព្រៃស ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ មានទំនាស់ដីធ្លីជាមួយនឹងលោក អ៊ិន សាម៉ុន ជាអគ្គលេខាធិការរងក្រសួងមហាផ្ទៃ តាំងពីឆ្នាំ២០០៧ កន្លងមក ប៉ុន្តែនៅមិនទាន់មានដំណោះស្រាយនៅឡើយទេរហូតមកទល់ពេលនេះ។ ហេតុដូចនេះហើយ បានជាធ្វើឱ្យប្រជាពលរដ្ឋដែលរងគ្រោះទាំងនោះមិនអាចអត់ទ្រាំ ហើយបានរៀបចំធ្វើដំណើរមកធ្វើការតវ៉ានៅគេហដ្ឋានរបស់សម្តេចនាយករដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី០១ ខែមិនា ឆ្នាំ២០១០ ប៉ុន្តែត្រូវបានកងកម្លាំងនគរបាល ខ័ណ្ឌដង្កោ ធ្វើការបង្ក្រាបយ៉ាងធ្ងន់ធ្ងរ និងចាប់ឃាត់ខ្លួនប្រជាពលរដ្ឋមួយចំនួនទៀតផង។ ដោយសារតែមានហេតុការណ៍បង្ក្រាបនេះកើតឡើង ប្រជាពលរដ្ឋរងគ្រោះបានប្តឹងមកសមាគមអាដហុក ហើយសមាគមអាដហុកក៏បានចាត់បុគ្គលិកចុះធ្វើការស៊ើបអង្កេត និងឃ្លាំមើលទៅលើករណីនេះ។ ប៉ុន្តែជាលទ្ធផល នៅក្នុងព្រឹត្តិការណ៍ស៊ើបអង្កេតនោះ មន្ត្រីស៊ើបអង្កេតចំនួន៣នាក់ (២នាក់ មកពីសមាគមអាដហុក និង ១នាក់ មកពីអង្គការលីកាដូ) ត្រូវបាននគរបាលខណ្ឌ័មានជ័យ ចាប់ដកហូតយកម៉ាស៊ីនថតរូប ចំនួន៣ គ្រឿង ប៉ុន្តែរយៈពេល៣ម៉ោងក្រោយមក ទើបសមត្ថកិច្ចប៉ូលីសបានផ្តល់ម៉ាស៊ីនថតទាំង៣ នោះមកវិញ ប៉ុន្តែបានលុបចោលនូវរូបភាព ដែលអ្នកស៊ើបអង្កេតទាំងនោះថតបាន។

ទាក់ទិននឹងសកម្មភាពខាងលើនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម ចាត់ទុកថា ជាការគំរាមកំហែង និងការរារាំងដល់សកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្ស។ រីឯការលុបចោលរូបភាពនៅក្នុងម៉ាស៊ីនថត គឺជាអំពើបំផ្លិចបំផ្លាញនូវឯកសារ ដោយសារមិនមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ និងដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ក្នុងការដកហូត។ ចំណែកឯសកម្មភាពថតរូបនោះទៀតសោត មិនមែនជាលក្ខណៈខុសច្បាប់ទេ ដោយសារទង្វើនេះ បានធ្វើឡើងនៅតាមទីធ្លាសាធារណៈជាក់ស្តែង។

គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធ មេត្តាចាត់វិធានការតាមផ្លូវច្បាប់ទៅលើមន្ត្រីដែលបានប្រព្រឹត្តខុសច្បាប់ខាងលើនេះ ដើម្បីជួយលើកស្ទួយសិទ្ធិទទួលបានព័ត៌មាន ក៏ដូចជាដើម្បីឱ្យសាកសមជាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ និង គោរពសិទ្ធិមនុស្សផងដែរ។

*ភ្នំពេញ ថ្ងៃទី០១ ខែមិនា ឆ្នាំ ២០១០*

☏ ***សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:***

| | | |
|---|---|---|
| លោក ហង្ស ឆាយា | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក នី ចរិយា | អ្នកសំរបសំរួលកម្មវិធី នៃសមាគមអាដហុក | ទូរស័ព្ទលេខ: ០១១ ២៧៤ ៩៥៩ |
| លោក សុក សំអឿន | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោកស្រី ស៊ុន ចាន់សែន | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី សយ សារាវឌ្ឍនី | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |